

# វេទិកាជាតិលើកទីពីរស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា

ថ្ងៃទី ៣_៥ ខែ តុលា ឆ្នាំ ២០១១

## តំបន់ការពារធម្មជាតិ និងវាលភក់ នៅកម្ពុជា


David Ashwell

ក្នុងនាម

មជ្ឈមណ្ឌលដើម្បីកិច្ចផ្តួចផ្តើមគោលនយោបាយស្អាត និងប្រព័ន្ធអេកូឡូស៊ី

# តំបន់ការពារធម្មជាតិកម្ពុជា



# ប្រព័ន្ធតំបន់ការពារធម្មជាតិកម្ពុជា



# ភាពជាតំណាង

- ជាទូទៅល្អ
  - មានជំពូកព្រៃឈើជាច្រើនជាតំណាងនៅក្នុងតំបន់ការពារធម្មជាតិ
  - មានប្រភេទសត្វដែលមានសារៈសំខាន់ជាអន្តរជាតិសម្រាប់ការអភិរក្សដែលស្ថិតនៅក្នុងតំបន់ការពារ
- ភាពខ្វះចន្លោះមួយចំនួន
  - ព្រៃស្រោងស្ងួត (ឧទាហរណ៍អំពីភាពធន់ទ្រាំដ៏ល្អមួយ)
  - ប្រព័ន្ធអេកូឡូស៊ីតំបន់ថ្មកំបោរ
  - តំបន់ទំនាបលិចទឹកស្ទឹងសែន (បឹងទន្លេសាប)
  - ប្រព័ន្ធអេកូឡូស៊ីដែនកោះនិងសមុទ្រ
- ១៥-១៨ % នៃផ្ទៃដីអាចជាតំណាងឱ្យចំណុចដៅសម្រាប់ការអភិរក្ស *ប្រសិនបើ*
  - បានចាត់ជាតំបន់ស្នូល និងតំបន់អភិរក្ស
  - បានទទួលការគាំទ្រតាមរយៈចំណាត់ជាតំបន់គ្រប់គ្រងបន្ថែមទៀត (នៅក្នុង និង/ឬនៅក្រៅតំបន់ការពារធម្មជាតិ)

- ការវិភាគភាពខ្វះចន្លោះនៅក្នុងគម្រោង BPAMP ឆ្នាំ 2007

# ការបែងចែកជាតំបន់គ្រប់គ្រង

- តំបន់ស្នូល : *ជាតំបន់មួយដែលមានគុណតម្លៃខ្ពស់ខាងការអភិរក្ស* ប្រភេទសត្វនិងរុក្ខជាតិដែលមានដោយកម្រ ជិតផុតពូជ ងាយរងគ្រោះ និងក្រោមការគំរាមកំហែង និងប្រព័ន្ធអេកូឡូស៊ីដែលផុយស្រួយ
- តំបន់អភិរក្ស : ជាតំបន់មួយ*នៅជាប់នឹងតំបន់ស្នូល* ដែលមានតម្លៃសម្រាប់ការអភិរក្សធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី តំបន់ចំណោត និងតំបន់ទេសភាពធម្មជាតិ។ ការចូលក្នុងតំបន់នេះត្រូវមានការអនុញ្ញាតជាមុនពីរដ្ឋបាលការពារ និងអភិរក្សធនធានធម្មជាតិនៅតាមទីតាំងនោះ។ *ការប្រើប្រាស់អនុផលព្រៃឈើ សម្រាប់ការចិញ្ចឹមជីវិតពីសំណាក់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច* និងត្រូវបង្កការខូចខាតដល់ជីវៈចម្រុះឡើយនិងត្រូវស្ថិតក្រោមការតាមដានតឹងរ៉ឹងបំផុត។
- តំបន់ប្រើប្រាស់ច្រើនយ៉ាង : ជាតំបន់មួយដែលមានគុណតម្លៃខ្ពស់សម្រាប់សេដ្ឋកិច្ចជាតិ ដែលផ្តល់ជាប្រយោជន៍ដោយ្ទាល់សម្រាប់គោលបំណងនៃការគ្រប់គ្រង និងការអភិរក្សតំបន់ការពារធម្មជាតិ និងរួមចំណែកដល់ការលើកកំពស់ ស្តង់ដារនៃការរស់នៅរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច។
- តំបន់សហគមន៍មូលដ្ឋាន : ជាតំបន់មួយដែល*សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច* ដែលមានសកម្មភាពនៅក្នុងតំបន់នោះរួចមកហើយ ដែលរួមទាំង ការសាងសង់ផ្ទះសំបែង ដាំដំណាំ និងសួនបន្លែ។ ការចេញលិខិតអនុញ្ញាត ឬ អាជ្ញាប័ណ្ណសម្រាប់ការប្រើប្រាស់ដីនៅក្នុងតំបន់នេះ ត្រូវធ្វើឡើងដោយក្រសួងបរិស្ថាន។

- ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ ២០០៩

# ស្ថានភាព : ភាពងាយរងគ្រោះ

- ៤១% នៃតំបន់ការពារធម្មជាតិ បានរងការខូចខាតរួចមកហើយ ឬ ងាយរងគ្រោះនៅចំពោះមុខការឥទ្ធិពលនានា
- ៥៧% នៃតំបន់ការពារធម្មជាតិ ស្ថិតនៅទីតាំងឆ្ងាយដាច់ស្រយាល

# គោលនយោបាយ



# គោលនយោបាយ

- មានបំណងជាជម្រើសគោលនយោបាយ ដែលបង្ហាញពីរបៀបអភិវឌ្ឍន៍តំបន់ការពារធម្មជាតិ ដែលគាំទ្រដល់កម្មវិធីជាតិស្តីពីរ៉ែ
- មានចែងអំពី
  - គោលការណ៍រួម
  - ធាតុសំខាន់ៗនៃគោលនយោបាយ
  - ឧបសគ្គ និងការប្រឈមនានា
  - ការណែនាំសម្រាប់អនុវត្ត

# គោលការណ៍សម្រាប់បង្កើតគោលនយោបាយ

*គោលការណ៍នានាខាងក្រោមនេះថែងអំពីលក្ខខណ្ឌស្នូលនៃគោលនយោបាយសម្រាប់តំបន់ការពារធម្មជាតិ :*

- កម្មវិធីរេដបូក គួរតែថែរក្សា និងពង្រឹងគុណតម្លៃកាបូន និងជីវៈចម្រុះនៅក្នុងតំបន់ការពារធម្មជាតិ និងព្រៃការពារ
- រេដគួរចាត់ជាអាទិភាពនូវព្រៃឈើក្នុងតំបន់ការពារធម្មជាតិ ដែលរួមទាំង ព្រៃចំណាស់ និងព្រៃរេចរឹល ដែលមាននាទីជាឃ្លាំងស្តុកកាបូន និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ
- គួរផ្តោតការយកចិត្តទុកដាក់លើ
  - ការលុបបំបាត់នូវការលេចធ្លាយ
  - ពង្រឹងស្តុកកាបូន តាមរយៈការស្តារព្រៃរេចរឹលឡើងវិញ និងការពារតំបន់ព្រៃឈើដែលងាយរងការខូចខាត
- ភាពបំពេញគ្នារវាងរេដ និងអនុសញ្ញាស្តីពីជីវៈចម្រុះ គួរត្រូវបានពង្រឹង ដើម្បីបង្កើនការគ្រប់គ្រងតំបន់ការពារធម្មជាតិនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងមូលដ្ឋាន
- រេដគួរតែប្រកាន់យកអភិក្រមប្រព័ន្ធអេកូឡូស៊ី ដែលមានគោលដៅធានាការពារតំបន់ទេសភាពដោយពង្រឹងភាពតជាប់គ្នាបានសមស្របរវាងតំបន់ធម្មជាតិនានា។

# ធាតុសំខាន់ៗនៃគោលនយោបាយ

- ផែនការជាតិស្តីពីតំបន់ការពារធម្មជាតិ (NPASMP)
- ស្តារតំបន់ព្រៃរេចរឹលឡើងវិញ
- ការចាត់ជាតំបន់គ្រប់គ្រង
- ការធ្វើវិមជ្ឈការ
- រចនាសម្ព័ន្ធមូលនិធិ

# មេរៀនទទួលបានពីករណីសិក្សាអំពីការវិភាគថ្លៃឱកាស

- ថ្លៃចំណាយសរុបជាមធ្យមសម្រាប់ការពារស្តុកកាបូន (៥ ទៅ ១២,៥ដុល្លា ក្នុងកាបូនមួយតោន) មានកម្រិតខ្ពស់ជាងថ្លៃលក់នៅតាមទីផ្សារស្ម័គ្រចិត្តភាគច្រើនក្នុងពេលបច្ចុប្បន្ននេះ
- ថ្លៃលើទីផ្សារជាប់កាតព្វកិច្ច ទំនងជាអាចផ្តល់ហិរញ្ញវត្ថុខ្ពស់ជាងយ៉ាងច្រើនសម្រាប់ប្រទេសនេះ
- ផលចំណូលបន្ថែមអាចបានមកតាមរយៈការបង្កើនសន្និធិកាបូន ដោយស្តារព្រៃឈើឡើងវិញ

# ផែនការប្រព័ន្ធតំបន់ការពារធម្មជាតិរបស់ជាតិ

- ចាត់ជាអាទិភាពនូវតម្រូវការឱ្យមានកិច្ចការពារ
- កំណត់អត្តសញ្ញាណការគំរាមកំហែងដែលមានបច្ចុប្បន្ន និងដែលទំនងជាកើតមានទៅអនាគត សម្រាប់តំបន់ការពារធម្មជាតិនីមួយៗ និងភាពពេញលេញនៃប្រព័ន្ធទាំងមូល
- កំណត់អត្តសញ្ញាណការគំរាមកំហែងនានានៅក្នុងតំបន់ការពារធម្មជាតិនីមួយៗ
- ប្រើប្រាស់ចំណាត់ជាតំបន់គ្រប់គ្រងជាឧបករណ៍សម្រាប់រួមបញ្ចូលទៅក្នុងកម្រងឱ្យមានប្រសិទ្ធភាព ការកសាងផែនការ និងការអនុវត្តនៅថ្នាក់តំបន់និងថ្នាក់ជាតិ
- ភាពបំពេញគ្នាជាមួយការកសាងផែនការនៅថ្នាក់តំបន់ និងការអនុវត្តនៅកម្រិតកម្រង
  - ពង្រឹងការចាត់ចែងស្ថាប័នសម្រាប់អនុវត្តសកម្មភាពនានា
  - ចាត់ជាអាទិភាព ដោយមានការវិភាជន៍ធនធាន និងការបណ្តុះបណ្តាល ព្រមទាំងការទទួលខុសត្រូវខាងស្ថាប័នឱ្យបានស្របគ្នានេះ។

# ការស្តារព្រៃឈើឡើងវិញ

*តំបន់ព្រៃឈើរេចរឹល និងព្រៃលូតលាស់ឡើងវិញជាច្រើនដែលសមស្របសម្រាប់*

- ការស្តារតំបន់ព្រៃធម្មជាតិឡើងវិញ និងទុកឱ្យតំបន់ព្រៃធម្មជាតិដុះលូតលាស់ឡើងវិញ
- ប្រព័ន្ធគ្រប់គ្រងបែបពាក់កណ្តាលធម្មជាតិ : កសិ-រុក្ខកម្មដោយផ្អែកលើប្រព័ន្ធអ៊ីប្រ៊ីដ
  - ដាំដំណាំដែលមានតម្លៃខ្ពស់ ដូចជាកាហ្វេ នៅក្នុងស្រទាប់ក្រោមនៃព្រៃឈើខ្ពស់ៗ
  - ការដាំបំពេញបន្ថែម ដោយប្រើប្រាស់ប្រភេទពូជធម្មជាតិ (ក្រឹស្នា ទេពីរូ)
- ប្រព័ន្ធគ្រប់គ្រងខ្លាំងក្លា : កសិ-រុក្ខកម្ម ឡូត៍ព្រៃឈើ រួមជាមួយសុវត្ថិកម្មព្រៃឈើ

# ការប្រៀបធៀបប្រព័ន្ធកំណត់តំបន់គ្រប់គ្រងជាមួយគោលបំណងនៃរេដបូក

- ប្រើប្រាស់ចំណាត់តំបន់គ្រប់គ្រង ជាឧបករណ៍សម្រាប់រួមបញ្ចូលកម្រងដែលមានប្រសិទ្ធភាព ការកសាងផែនការនៅថ្នាក់តំបន់ និងថ្នាក់ជាតិ និងការអនុវត្ត ដើម្បីការពារ និងបង្កើនស្តុកកាបូន
- តំបន់ប្រើប្រាស់ដោយនិរន្តរភាព : តំបន់ប្រើប្រាស់ដោយនិរន្តរភាព រួមបញ្ចូល ទីតាំងដូចតទៅ :
  - តំបន់បេតិកភណ្ឌវប្បធម៌របស់ជាតិ
  - តំបន់អេកូទេសចរណ៍
  - តំបន់អភិរក្សសត្វព្រៃ និងសេវាកម្មបម្រើការកំសាន្ត
  - តំបន់ស្តារស្ថានភាពជីវសាស្ត្រឡើងវិញ
  - ដែនសហគមន៍តំបន់ការពារធម្មជាតិ
  - សួនរុក្ខជាតិ
  - ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដែលរួមទាំង ប្រព័ន្ធស្រោចស្រព អាងទឹក វារីអគ្គិសនី បណ្តាញអគ្គិសនី
    - អាជីវកម្មរ៉ែ
    - ការធ្វើអាជីវកម្មជ័រដែលមិនបំផ្លាញបរិស្ថាន នៅក្នុងតំបន់ការពារធម្មជាតិ និងតំបន់ជុំវិញ.
- ការពង្រឹងស្តុកកាបូនអាចផ្តល់នូវហេតុផលខាងសេដ្ឋកិច្ចសម្រាប់ការប្រើប្រាស់ដីនៅក្នុងតំបន់ប្រើប្រាស់ដោយនិរន្តរភាព ដែលទ្រទ្រង់ដល់គុណតម្លៃនៃការអភិរក្ស និងផលប្រយោជន៍បន្ថែមផ្សេងទៀត

# ការចាត់ជាអាទិភាពសម្រាប់ការវិនិយោគលើការស្តារឡើងវិញ

- ប្រព័ន្ធបែងចែកជាតំបន់គ្រប់គ្រង ផ្តល់ឱកាសសម្រាប់ពង្រឹងផលស្តុកកាបូន នៅក្រោមក្របខ័ណ្ឌរ៉េដ
  - ការពង្រឹងស្តុកកាបូននៅក្នុងតំបន់ព្រៃមិនរេចរឹល ដែលចាត់ជាតំបន់ស្នូល តំបន់អភិរក្ស
  - ការស្តារព្រៃឈើឡើងវិញ និងការរក្សាទុកឱ្យព្រៃឈើដុះលូតលាស់ឡើងវិញ អាចផ្តោតលើតំបន់ស្នូល តំបន់អភិរក្ស និងតំបន់ប្រើប្រាស់ដោយនិរន្តរភាព
  - ប្រព័ន្ធគ្រប់គ្រងបែបនេះ ត្រូវតែកំហិតឱ្យមាននៅត្រឹមតំបន់ប្រើប្រាស់ដោយនិរន្តរភាព និងតំបន់សហគមន៍មូលដ្ឋានប៉ុណ្ណោះ។
- កន្លែងនានាដែលមានការរេចរឹលខ្លាំង និងមិនអាចស្តារឡើងវិញបាន គួរតែដាក់ក្រោមការពិចារណាដើម្បីកាត់ចេញពីប្រព័ន្ធតំបន់ការពារធម្មជាតិ។

# វិមជ្ឈការ

- រ៉េដបូក មិនមែនជាដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឡើយ។ វត្តមានយ៉ាងសកម្មនិងសម្រាប់រយៈពេលយូរនៅក្នុង ព្រៃឈើកន្លែងណាមួយ ទាមទារឱ្យមាន :
  - ការគ្រប់គ្រងជាប់ជាប្រចាំ នៅក្នុងពេលវេលាជាច្រើនជំនាន់មនុស្ស និងទាមទារឱ្យអនុម័តផែនការ និងវិធានការនានាយ៉ាងមានប្រសិទ្ធភាព
  - ការប្រាស្រ័យទាក់ទងជាប់ជាប្រចាំ និងយ៉ាងមានប្រសិទ្ធភាព
  - បង្កើតឱ្យមានចំណាត់ការឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៅនឹងកន្លែងបានទាន់ពេលវេលា ដូចជា ភ្លើងព្រៃ ការរំលោភយកដីធ្លី ការលួចចូលចាប់សត្វ។ល។
- លក្ខខណ្ឌដើម្បីឱ្យមានវត្តមានសម្រាប់រយៈពេលវែងអាចធ្វើបាន តាមរយៈការវិនិយោគលើការកសាងសមត្ថភាពខាងស្ថាប័ន ការចាត់ចែង និងសមត្ថភាពខាងធនធានមនុស្សនៅថ្នាក់ក្រោមជាតិ ដូចជា ភូមិ ឃុំ ស្រុក
- ការខកខាននឹងនឹងនាំមកនូវការខូចខាតផលប្រយោជន៍ជាក់ស្តែង និងដែលធ្វើឱ្យអ្នកពាក់ព័ន្ធទាំងអស់គ្នាខូចផលប្រយោជន៍
- ការចែកផលទាមទារឱ្យ
  - ផលចំណូលដែលទាក់ទងនឹងការអភិរក្សព្រៃឈើ ត្រូវបានបែងចែកដោយសមធម៌ និងមានតម្លាភាព ដល់អ្នកទាំងអស់ដែលចូលរួមនៅក្នុងការងារនេះ
  - ត្រូវមានគំរូនៃផលចំណូលពីរបែប ដើម្បីទ្រទ្រង់ការចិញ្ចឹមជីវិតឱ្យមាននិរន្តរភាព និងការវិនិយោគលើពេលវេលា និងធនធានរបស់សហគមន៍  លើសកម្មភាពប្រើប្រាស់ដែលមាននិរន្តរភាព
  - ការទទួលបានឥណទានកាបូនជាទៀងទាត់ មានសារៈសំខាន់ណាស់សម្រាប់អ្នកពាក់ព័ន្ធទាំងអស់

# រចនាសម្ព័ន្ធមូលនិធិ

- មូលនិធិរួមគ្នារវាងការអភិរក្ស និងរ៉េដបូក
  - ធានាឱ្យមានសង្គតិភាពលើការគ្រប់គ្រងតំបន់ការពារធម្មជាតិ
  - អាចអនុវត្តបានតាមរយៈកម្រង ឬ តំបន់ការពារធម្មជាតិនីមួយៗ តែមិនមែនជាការបែងចែកជាតំបន់គ្រប់គ្រងឡើយ
- ការផ្តល់មូលនិធិសម្រាប់អភិរក្ស ត្រូវធ្វើឱ្យមានតុល្យភាពជាមួយមូលនិធិសម្រាប់រ៉េដ តាមរយៈរដ្ឋាភិបាលមូលដ្ឋាន ដើម្បីថានាថា គោលបំណងនៃតំបន់ការពារធម្មជាតិត្រូវបានប្រកាន់យកជាគោលដៅបឋម
- យុទ្ធសាស្រ្តជាតិស្តីពីរ៉េដ ដែលរួមបញ្ចូលគោលបំណងនានា (ដូចជា ជីវៈចម្រុះ ការអភិវឌ្ឍនៅមូលដ្ឋាន ជនជាតិដើម) នឹងកាន់តែ :
  - មានការទាក់ទាញទឹកចិត្តពីសំណាក់ម្ចាស់ជំនួយអន្តរជាតិ និងទំនងជាបានទទួលការគាំទ្រមូលនិធិជាបន្ថែម

# ឧបសគ្គ និងការប្រឈមនានា



# នៅកម្រិតម៉ាក្រូ

- ការគ្រប់គ្រងលើការគំរាមកំហែង
  - ការសម្របសម្រួលអន្តរវិស័យ និងរវាងវិស័យនានានៃសកម្មភាពអនុវត្តនៅមានកម្រិតកំណត់នៅឡើយ
    - គោលបំណងនៃការប្រើប្រាស់ដី នៅពុំទាន់ធ្វើឱ្យមានភាពចុះសម្រុងគ្នានៅឡើយ
  - ការអនុវត្តផែនការប្រើប្រាស់ដីដែលមានស្រាប់ធ្វើឡើងជាលក្ខណៈបណ្តោះអាសន្ន និងពុំមានសង្គតិភាពនៅឡើយ ដូចជា ការឱ្យអាទិភាព លើដីសម្បទានសេដ្ឋកិច្ច ខ្ពស់ជាងដំណើរការកសាងផែនការនៅមូលដ្ឋាន
  - ការបន្តមិនយកចិត្តទុកដាក់លើសិទ្ធិរបស់ជនជាតិដើមភាគតិចចំពោះដីធ្លី ដូចមានចែងនៅក្នុងច្បាប់
- ការកសាងផែនការប្រើប្រាស់ដីនៅកម្រិតជាតិ និងកម្រិតតំបន់
  - កង្វះការសម្របសម្រួលលើការធ្វើសេចក្តីសម្រេចអំពីការប្រើប្រាស់ដី
    - តាមខ្សែទទឹង និងខ្សែបណ្តោយ
  - ការមិនយកចិត្តទុកដាក់លើសិទ្ធរបស់ជនជាតិដើមដូចមានចែងក្នុងច្បាប់
  - ទំនាស់ផលប្រយោជន៍នៃអ្នកដែលមានតួនាទីជាអ្នកកសាងផែនការប្រើប្រាស់ដីផង និងជាអ្នកគ្រប់គ្រងដីធ្លីផង
    - ភាពប្រកួតប្រជែងនៅក្នុង និងរវាងក្រសួងនានា
- ព្រំប្រទល់
  - ការកំណត់ព្រំប្រទល់នៅពុំទាន់បានធ្វើគ្រប់គ្រាន់នៅឡើយ
  - កង្វះការកំណត់ព្រំប្រទល់
- ពុំមានការអនុវត្តច្បាប់បានគ្រប់គ្រាន់នៅឡើយ

# នៅកម្រិតមីក្រូ

- ការគ្រប់គ្រងធនធាននៅថ្នាក់ឃុំ រងការប៉ះទង្គិចជាច្រើន ដែលធ្វើឱ្យការកសាងផែនការ និងការអនុវត្តមិនភាពមិនដាច់ស្រេច
  - ការកសាងផែនការនៅថ្នាក់មូលដ្ឋានសម្រាប់រយៈពេលខ្លីៗតែប៉ុណ្ណោះ
  - កំណើនយ៉ាងឆាប់រហ័ស និងការធ្លាក់ចុះនៃគម្រោងវិនិយោគ
  - សកម្មភាពប្រើប្រាស់ដីធ្លី និងធនធានដោយល្មើសច្បាប់ពីសំណាក់អ្នកមកពីក្រៅ
- សមត្ថភាពឆ្លើយតបនៅមានកម្រិតទាបសម្រាប់ដោះស្រាយបញ្ហានានា
  - ការបង្កើនការយល់ដឹងអំពីគោលបំណង និងនីតិវិធីរ៉េដបូកនៅមានកម្រិតនៅឡើយ
  - ការលើកទឹកចិត្តដើម្បីឱ្យមានការចូលរួមពេញលេញនៅពុំទាន់មានគ្រប់គ្រាន់នៅឡើយ
  - ទំនាស់ដែលនៅពុំទាន់ដោះស្រាយបាន - បុគ្គល សហគមន៍ ជំនួញ និងអាជ្ញាធរ
- ពុំមានការតាមដានដោយភាគីឯករាជ្យទីបី (ដោយពុំជាប់ពាក់ព័ន្ធនឹងប្រយោជន៍ក្នុងកម្មវិធីនេះ)
  - NCDD បច្ចុប្បន្ននេះកំពុងអនុវត្តសាកល្បងជាមួយ NGOs

# អនុសាសន៍



# ការណែនាំសម្រាប់អនុវត្តគោលនយោបាយ

- រចនាសម្ព័ន្ធវិមជ្ឈការសម្រាប់ការអនុវត្ត
  - ឃុំ និងស្រុក គឺជាមូលដ្ឋានគ្រឹះសម្រាប់ការអនុវត្តរេដបូក
  - អាចពង្រឹងជាបន្ថែមលើសមត្ថភាពដែលមានស្រាប់ - NCDD, CLUP, CPAs, CFAs, ។ល។
  - ប្រើប្រាស់ប្រព័ន្ធរដ្ឋបាលដែលបានបង្កើតរួចហើយ ដើម្បីថានាឱ្យមាន :
    - ការចូលរួមយ៉ាងសកម្មនៅថ្នាក់មូលដ្ឋាន ដើម្បីដោះស្រាយបញ្ហានានាឱ្យបានឆាប់រហ័ស
    - ការទូទាត់ប្រចាំត្រីមាសដែលបានឃើញថាកើតមានជាទៀងទាត់
- ការតាមដានដោយភាគីទីបី — ឯករាជ្យដាច់ចេញពីការអនុវត្ត
- អភិក្រមកម្រង នៅក្នុងការកសាងផែនការ និងការអនុវត្តតំបន់ការពារធម្មជាតិ ដោយផ្អែកលើតំបន់ជីវសាស្ត្រ។

# ក្របខ័ណ្ឌប្រចាំតំបន់



# ការណែនាំបច្ចេកទេស

- បង្កើតក្របខ័ណ្ឌអេកូឡូស៊ីសម្រាប់ជំពូកព្រៃឈើ ដោយផ្អែកលើគោលគំនិងអំពីលក្ខណៈឌីណាមិក នៃសហគមន៍រុក្ខជាតិ ដែលជាមូលដ្ឋានសម្រាប់ការកំណត់អត្តសញ្ញាណ
  - ទម្រង់នៃភូតគាម  ទម្រង់នៃការលូតលាស់នៃរុក្ខជាតិ និងបរិស្ថាន
  - អាទិភាពនៃការអភិរក្ស
  - កែលម្អរង្វាស់ភាពរេចរឹលនៃព្រៃឈើ
  - អាទិភាព និងលំនាំនៃការស្តារព្រៃឈើឡើងវិញ
- កែលម្អសមត្ថភាពខាងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ
  - ប្រើប្រាស់ទិន្នន័យថតពីផ្កាយរណប សម្រាប់វាស់ស្តុកកាបូន និងលំហូរកាបូនព្រៃឈើ
  - សារពើភ័ណ្ឌសហគមន៍រុក្ខជាតិ — ត្រូវការអ្នកជំនាញអេកូឡូស៊ីរុក្ខជាតិ
- កែតម្រូវព្រំប្រទល់តំបន់ការពារធម្មជាតិ និងតំបន់គ្រប់គ្រង
  - ការទទួលស្គាល់ និងការប្រតិបត្តិបាន
- បង្កើតប្រព័ន្ធបែងចែកជាតំបន់គ្រប់គ្រងព្រៃការពារ ដោយផ្អែកលើវិសាលភាពនៅកម្រិតតំបន់ ជាងលើតំបន់ការពារនីមួយៗដាច់តែឯង

# មុខនាទី : លំនាំទៅរកកិច្ចការពារ



# សូមអរគុណ!



For more information:

*www.ccap.org*